ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៥២/១១-យីងឡា**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន យីងឡា (ខេមបូឌា ) នីតធីង**

អាសយដ្ឋាន : ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៨៥១ ៥០៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ :

| | |
|---|---|
| ១- លោកស្រី Wang Furong | នាយិកាក្រុមហ៊ុន |
| ២- លោក ចៅ ផេង | ប្រធានរដ្ឋបាល |

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ :

| | |
|---|---|
| ១- លោកស្រី Wang Furong | នាយិកាក្រុមហ៊ុន |
| ២- លោក ចៅ ផេង | ប្រធានរដ្ឋបាល |



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- ភាគីកម្មករនិយោជិត

ឈ្មោះ : ~ **សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

~ **សហជីពសម្លេងយុវជនខ្មែរ នៃក្រុមហ៊ុន យីងឌា**

អាសយដ្ឋាន : ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៧១៣ ០៦៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ :

១- លោក លី ធី មន្ត្រីសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ

២- លោក ពៅ ប៊ុនធឿន ប្រធានសហជីពសម្លេងយុវជនខ្មែរនៃក្រុមហ៊ុន យីងឌា

៣- លោក ស្រេង វ៉ាន់ធី អនុប្រធានសហជីព

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ : **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពសម្លេងយុវជនខ្មែរចំនួនពីររូបមានឈ្មោះ ពៅ ប៊ុនធឿន តួនាទីប្រធានសហជីព, លោក ស្រេង វ៉ាន់ធី ជាអនុប្រធានសហជីព និងកម្មករចំនួន ០៨ នាក់ទៀតឱ្យចូលធ្វើការវិញ និងរំលឹកប្រាក់ឈ្នួលរហូតដល់ថ្ងៃធ្វើការវិញ ។

២- សុំឱ្យក្រុមហ៊ុនបន្តកិច្ចសន្យារបស់កម្មករម្តងមួយឆ្នាំ ។

៣- សុំឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូននៅក្នុងក្រុមហ៊ុន ។

៤- សុំឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកសាជាថ្មី ។

៥- សុំឱ្យក្រុមហ៊ុនកុំធ្វើការរើសអើងចំពោះកម្មករទាំងឡាយណាដែលបានចូលរួមជាសមាជិកសហជីព ។

៦- សុំឱ្យក្រុមហ៊ុនតម្លើងប្រាក់អតីតភាពការងារចាប់ពី ០៥ ឆ្នាំឡើងទៅ បន្ថែម ០១ ដុល្លាររហូតរៀងរាល់ខែមិនកំណត់ ។

៧- សុំឱ្យក្រុមហ៊ុនតម្លើងលុយថ្លៃបាយជូនកម្មករថែមម៉ោងត្រឹមម៉ោង ៦:០០ នាទី. ៣០០ រៀល ។

៨- សុំឱ្យក្រុមហ៊ុនចេញថ្លៃស្នាក់នៅ ឬសោហ៊ុយធ្វើដំណើរក្នុងម្នាក់ ១០ ដុល្លារក្នុងមួយខែ ។

៩- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ការងារទៀងទាត់ (លុយព្រីម) ១០ ដុល្លារក្នុងមួយខែ ។

១០- នៅពេលកម្មករសុំច្បាប់មានធុរៈម្តងម្កាលសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ១៧៣/១១ កប/កណ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១។

### សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** - លើកទី១ : ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទីរសៀល)។
- លើកទី២ : ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្ដាល បានទទួលបណ្តឹងរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ស្ដីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន១០ចំណុច។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្ដាលបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងារនេះនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១០ ចំណុច លើការទាមទារចំនួន ១០ ចំណុច។ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃីងឌា ខេមបូឌា នីតធីង លេខ ០៧៣/១១ កប/កណ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ១៤:០០ នាទី រសៀល។ នៅថ្ងៃសវនាការនេះ ភាគីខាងសហព័ន្ធ និងសហជីពមូលដ្ឋានបានស្នើសុំក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងភាគីនិយោជក ដើម្បីលើកពេលសវនាការទៅថ្ងៃក្រោយវិញ ព្រោះពួកគាត់ដែលបានចូលរួមនេះ មិនមានអ្នកណាម្នាក់បានដឹងច្បាស់លាស់ពាក់ព័ន្ធ

នឹងចំណុចវិវាទទាំងអស់នោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីនិយោជកក៏ឯកភាពក្នុងការលើកពេលសវនាការនេះទៅថ្ងៃក្រោយតាមសំណូមពរ។

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង០៨:៣០ព្រឹក ជាថ្ងៃសវនាការលើកទី២ ដែលបានកំណត់។ នៅថ្ងៃសវនាការ ភាគីនិយោជកបានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយបានបញ្ជាក់ថា ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តនីតិវិធីរបស់ខ្លួនបន្តទៀត ដោយមិនមានភាគីសហជីពចូលរួមទេ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- សារណាសង្ខេបនៃវិវាទការងារ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ ។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន យីងឌា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន យីងឌា ចុះបញ្ជិកាលេខ ៥៨៨/១០ កបវ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។

៤- កិច្ចសន្យាការងារ និងប្រវត្តិរូបសង្ខេបរបស់លោក ស្រេង វ៉ាន់ធី ។

៥- កិច្ចសន្យាការងារ និងប្រវត្តិរូបសង្ខេបរបស់លោក ពៅ ប៊ុនធឿន ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យីងឌា លេខ ១៧៣/១១ កប/កណ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យីងឌា ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ២៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ២៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៣៧២ កប/អក/វក/លកអ. ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៣៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា សហជីពសម្លេងយុវជនខ្មែរប្រចាំក្រុមហ៊ុនអវត្តមាននៅថ្ងៃសវនាការ ដោយគ្មានបញ្ជាក់មូលហេតុ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតមិនបានចូលរួមនៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញទេ។ ភាគីកម្មករនិយោជិតមិនបានបញ្ជាក់ពីមូលហេតុត្រឹមត្រូវពីការមិនមកចូលរួមសវនាការនេះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោមៈ

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់... "*។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេល ដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ "* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី និងលេខ ២៧/០៧-អ៊ីម និង វ៉េ ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងបាន *"លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "* ។

យោងតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩

សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះយល់ឃើញថា ក្រុមអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងទៅ តាមលក្ខខណ្ឌទាំងបីនោះ គឺ លក្ខខណ្ឌទី១ : *ភាគីបានទទួលការអញ្ជើញត្រឹមត្រូវ* លក្ខខណ្ឌទី២ : *ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល* និងលក្ខខណ្ឌទី៣: *ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន*។

ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : *ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ***

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិតមកចូលរួមសវនាការអាជ្ញាកណ្តាលត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៣៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការ-ដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ **ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី ២ : *ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ *"បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះមានន័យថា ភាគីត្រូវតែចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់ការណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់ការពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់ការផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ កម្មករនិយោជិតមិនបានចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី ២ ក៏ត្រូវបានបំពេញដែរ។**

**<u>លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន</u>**

ក្នុងករណីនេះ កម្មករនិយោជិតមិនបានផ្តល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ដោយភាគីកម្មករនិយោជិតបានបញ្ជាក់ថា ខ្លួនមិនមកចូលរួមសវនាការបានទេ ហើយសុំឱ្យអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់តាមនីតិវិធីចុះ។ ចំណែកឯភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា **<u>ភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួន</u>នេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី ៣ ក៏ត្រូវបានបំពេញដែរ។**

ដូច្នេះ ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់កម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងក្នុងការធ្វើការការពារ ចំពោះការទាមទាររបស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានជ្រើសរើសការមិនចូលរួមនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមានចេតនាមិនចូលរួមដោះស្រាយ ជំលោះរបស់ខ្លួនជាមួយនិយោជកតាមនីតិវិធី ដែលច្បាប់តម្រូវនោះឡើយ។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណីភាគីដើមបណ្តឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីកម្មករនិយោជិតក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ៥២/១១- ឃីងឌា នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

*- បិទសំណុំរឿងលេខ ៥២/១១- ឃីងឌា ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ឹង សុទ្ធី**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **ទួន ស៊ីផាន់**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល :**

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------